កាលបរិច្ឆេទៈ ថ្ងៃទី ២០ ខែមីនា ឆ្នាំ២០១៩

# មេរៀនដំណាំថ្មី(ស)

## បច្ចេកទេសនៃការដាំដំណាំថ្មីស

### ១.ការរៀបចំដី

- ភ្ជួរដីហាលដីរយៈពេលពី៧-១៥ថ្ងៃ
- ត្រូវភ្ជួររាស់ប្រែដីឱ្យបាន២ទៅ៣ដងក្នុងជម្រៅពី២ទៅ៣តឹក។

### ២.ការរៀបចំរងឬថ្នាល

☺ ធ្វើរងទទឹងយកប្រវែង១ម៉ែត្រ បណ្ដោយតាមលទ្ធភាពដី

☺ ត្រូវលើកកំពស់រងពី១០-២៥ស.ម បណ្ដោយរងប្រវែង១០ម៉ែត្រ

☺ ចន្លោះពីរងមួយទៅរងមួយយកប្រវែងពី២,៥តឹក-៣តឹក

☺ ត្រូវប្រើជីធម្មជាតិឬជីកំប៉ុស្តិ៍សម្រាប់ទ្រាប់បាតចំនួន២០-២៥បង្គី។

### ៣.ការដាំដុះ

○ ត្រូវធ្វើដីរងឬថ្នាលឱ្យបានស្អាតល្អ និងច្របល់ជីធម្មជាតិជាមួយដីរងឱ្យបានសព្វល្អ។

រៀបចំដោយ លោក យុគ សឿង នាយករងរបស់អង្គការស៊ីអារ៍ឌីណាស់ (CRDNASE)
កែសម្រួលអត្ថបទដោយ ស៊ុន សុគន្ធី មន្ត្រីគម្រោងរបស់អង្គការស៊ីអារ៍ឌីណាស់ (CRDNASE)

- យកគ្រាប់ពូជផ្ទីមកហាលថ្ងៃរយៈពេលពី៣០ទៅ៥០នាទី
- យកគ្រាប់ពូជត្រាំទឹករយៈពេលពី២ទៅ៣ម៉ោង រួចផ្អាប់១យប់
- យកខ្សាច់៤ភាគច្របល់ជាមួយគ្រាប់ពូជឱ្យបានសព្វល្អ បន្ទាប់មកយកវាទៅព្រោះលើថ្នាលស្តើងៗល្មម។
- រោយអំពុកចំបើង(បើមាន) រួចហើយស្រោចទឹកឱ្យជោគ។

**<u>ករណីមួយទៀត៖</u>**

- គ្រាប់ពូជមិនចាំបាច់ត្រាំទឹកទេ បន្ទាប់ពីហាលថ្ងៃរួចអាចយកវាទៅព្រោះបាន។
- គ្រាប់ពូជចាប់ផ្តើមដុះពន្លកក្រោយពីព្រោះបាន៣ទៅ៥ថ្ងៃ
- នៅពេលកូនផ្ទីដុះបានពី៧ទៅ១០ថ្ងៃ អាចដកយកទៅស្ទូងឬជួសបានឬកំពស់២ថ្នាំងដៃ ដោយចន្លោះពីគុម្ពមួយទៅគុម្ពមួយប្រវែង១ទៅ២តឹកឬ២ទៅ៣តឹក។

## ៤.ការថែទាំ

- ☺ ត្រូវស្រោចទឹកឱ្យបានសមស្រប កុំជោគជាំពេកបណ្តាលឱ្យរលួយ
- ☺ ត្រូវជ្រុំជើងឱ្យបានល្អ
- ☺ បោចស្មៅ មើលសត្វល្អិតនិងដាក់ជី។

រៀបចំដោយ លោក យុគ សឿង នាយករងរបស់អង្គការស៊ីអារ៍ឌីណាស់ (CRDNASE)
កែសម្រួលអត្ថបទដោយ ស៊ុន សុគន្ធី មន្ត្រីគម្រោងរបស់អង្គការស៊ីអារ៍ឌីណាស់ (CRDNASE)

## ៥.ការប្រមូលផល

- ការប្រមូលផលធ្វើឡើងនៅពេលដំណាំផ្ទីអាយុបាន២៥ទៅ៣០ថ្ងៃ
- អាចដកទាំងឫស ឬកាត់ស្លឹកត្រួយ ការកាត់ត្រួយអាចប្រមូលបានច្រើនលើក វាអាស្រ័យតាមទីផ្សារ។

## ៦.ការរក្សាពូជ

- ✓ ត្រូវទុកដើមឱ្យវាចេញផ្កាផ្លែ។ លុះផ្លែទុំល្អមហើយគេបូតវាដាក់ថង់ ហើយហាលថ្ងៃឱ្យស្ងួត។
- ✓ ញីឱ្យខ្ទេចរួចរោយយកគ្រាប់វារួចយកទៅហាលថ្ងៃម្តងទៀត រួចប្រចកដកទុកដាំដុះឆ្នាំក្រោយ។

**សូមអរគុណ**

រៀបចំដោយ លោក យុគ សឿង នាយករងរបស់អង្គការស៊ីអារ៍ឌីណាស់ (CRDNASE)
កែសម្រួលអត្ថបទដោយ ស៊ុន សុគន្ធី មន្ត្រីគម្រោងរបស់អង្គការស៊ីអារ៍ឌីណាស់ (CRDNASE)

កាលបរិច្ឆេទៈ ថ្ងៃទី ២០ ខែមីនា ឆ្នាំ២០១៩

# មេរៀនដាំសាឡាត់

## បច្ចេកទេសនៃការដាំសាឡាត់

### ក-ការរៀបចំដី

១) ភ្ជួរដីហាលចោលរយៈពេលពី៧ទៅ១៥ថ្ងៃ

២) ត្រូវភ្ជួររាស់ដីចំនួន២ឬ៣ដងដើម្បីឲ្យពពួកសត្វល្អិតចង្រៃស្លាប់ឲ្យស្មៅរលួយ ឲ្យដីមានជីជាតិ មានខ្យល់អុកស៊ីសែន និងធ្វើឲ្យដីធូនិងម៉ត់ល្អ។

៣) ភ្ជួរជម្រៅទៅក្នុងដីឲ្យបាន៣តឹកដើម្បីឲ្យដីមានសំណើមបានជ្រៅ និងធ្វើឱ្យដីធូ។

### ខ-ការរៀបចំថ្នាលនិងរង

១) ថ្នាលត្រូវធ្វើទទឹង១ម៉ែត្រឬ១,២ម៉ែត្រ បណ្តោយថ្នាលយកតាមតម្រូវការ ចំណែកឯកំពស់ថ្នាលយកប្រវែងពី១០ទៅ២០សង់ទីម៉ែត្រ ឬ២៥សង់ទីម៉ែត្រក៏បាន។

២) សំរាប់រងក៏ធ្វើដូចថ្នាលដែរតែបណ្តោយអាចវែង

រៀបចំដោយ លោក យុគ សឿង នាយករងរបស់អង្គការស៊ីអាវ៍ឌីណាស់ (CRDNASE)
កែសម្រួលអត្ថបទដោយ ស៊ុន សុគន្ធី មន្ត្រីគម្រោងរបស់អង្គការស៊ីអាវ៍ឌីណាស់ (CRDNASE)

៣) រងឬថ្នាលបណ្តោយ២០ម៉ែត្រ ត្រូវប្រើជីកំប៉ុស្តឬជីធម្មជាតិផ្សេងៗ ចំនួន២០ទៅ២៥បង្គី។

៤) ចន្លោះពីរងមួយទៅរងមួយឬចន្លោះផ្លូវដើរយកប្រវែងពី៣ទៅ៤តឹក

## គ-ការដាំដុះ

១) ក្រោយពីធ្វើថ្នាលរួចហើយត្រូវយកជីធម្មជាតិឬកំប៉ុស្តទៅរោយពីលើរួចច្របល់នឹងដីថ្នាលឲ្យបានចូលគ្នាល្អផង។

២) យកគ្រាប់ពូជខ្ទប់នឹងក្រណាត់រួចត្រាំទឹក១យប់ផ្អាប់១យប់ *(ពូជដែលនៅសល់ពីសាបត្រូវដាក់ក្នុងដបឬកំប៉ុងរួចបិទគំរបឲ្យជិតកុំឲ្យខ្យល់ចេញចូលរួច)*

៣) យកពូជដែលផ្អាប់រួចនោះទៅរោយឬសាបពីលើថ្នាលដែលបានរៀបចំទុកកាលពីពេលមុន។

៤) ត្រូវយកកំទេចចំបើងឬអំពុកចំបើងទៅរោយពីលើបន្ទាប់ពីសាបគ្រាប់រួច ដើម្បីការពារដំណក់ទឹកនិងរក្សាសំណើមបានយូ។

៥) ត្រូវធ្វើដំបូលការពារកំដៅថ្ងៃនិងទឹកភ្លៀងផង

៦) ក្រោយពីកូនសាឡាត់ដុះបានរយៈពេលពី១០ទៅ១៥ថ្ងៃគេអាចដកវាយកទៅស្ទូងបានត្រូវជ្រើសកូនណាដែលល្អ**ត្រូវចាំ** *មុនពេលដកកូនទៅស្ទូងត្រូវផ្អាកស្រោចទឹកនិងជីប៉ូវរយៈពេល២ថ្ងៃសិនទុកអោយដើមរឹងមាំ។*

៧) ត្រូវចាំពេលដាក់ជីកំប៉ុស្តនៅលើរងនោះត្រូវទុករយៈពេលពី២ទៅ៣ម៉ោងសិនដើម្បីឲ្យជីអស់កំសួលកំដៅសិនចាំដាំវាបើដាំឬស្ទូងភ្លាមៗវាអាចភាយកំដៅនឹងធ្វើឲ្យកូនដំណាំរលួយបាន ព្រោះវានៅមានសារធាតុអាម៉ូញាក់។

៨) ការដាំត្រូវដាំគំលាតគ្នាពីគុម្ពមួយទៅគុម្ពមួយប្រវែង១៥សង់ទីម៉ែត្រ និងត្រូវធ្វើដំបូលការពារកូនសន្ទូងរយៈពេល២ឬ៣ថ្ងៃចាំបើកវា។

## ឃ-ការថែទាំ

១) ស្រោចទឹកក្នុង១ថ្ងៃឲ្យបាន២ដងយ៉ាងតិចគឺព្រឹកនិងល្ងាច។

២) ក្រោយពីសាឡាត់ស្ទូងបានរយៈពេល៧ឬ៨ថ្ងៃ ត្រូវបោចស្មៅនិងជ្រោយដីជ្រុំជើង កុំទុកឲ្យស្មៅវែងពេក។

៣) ត្រូវប្រើប្រាស់ជីបំប៉នធម្មជាតិពេលសាឡាត់អាយុបាន៨ថ្ងៃ ត្រូវស្រោច៣ថ្ងៃស្រោចម្តងនិងពេលសាឡាត់អាយុ១២ថ្ងៃត្រូវស្រោច១អាទិត្យម្តង។

## ង-វិធីការពារ

១) ត្រូវដាំរុក្ខជាតិនៅក្បែរដើម្បីបន្លាចសត្វចង្រៃដូចជា ស្លឹកគ្រៃ ផ្កាស្បៃរឿងឬប្រើថ្នាំសំលាប់សត្វល្អិតដែលធ្វើពីធម្មជាតិ ទឹក១៧លីត្រនិងទឹកថ្នាំធម្មជាតិ ១លីត្រសំរាប់បាញ់។

- ***ថ្នាំធម្មជាតិ*** ដូចជា បណ្តូលពេជ្រ គ្រាប់ស្លែង មើមក្តួច ផ្លែស្លាក់ ប្រង់រំដេង ស្លឹកទាបបាយ។ល។ យកមកចិញ្ច្រាំឲ្យម៉ដ្ត រួចត្រាំទឹកផ្អាប់ទុករយៈ

ពេល១ខែ តែត្រូវឧស្សាហ៍កូរវាឲ្យបានញឹកញាប់ បន្ទាប់មកអាចចម្រស់វាដាក់ទុកក្នុងដបឬប៊ីដុងហើយទុកក្នុងកន្លែងត្រជាក់ល្អ។

➢ ***ជីប៉ូវធម្មជាតិ*** ចេកទុំ៣kg ស្ករត្នោត១kg ត្រសក់ស្រូវទុំ៣kg ល្ពៅទុំ៣kg យកវាមកចិញ្ច្រាំឲ្យម៉ដ្ឋ រួចច្របល់ចូលគ្នារួចផ្អាប់ទុករយៈពេល១ខែអាចចម្រស់វាមកប្រើបាន។

➢ ***របៀបប្រើ*** កូនដំណាំតូច *ជី២ស្លាព្រាបាយនិងទឹក២០លីត្រ* សំរាប់ដំណាំពីតូចដល់អាយុ២០ថ្ងៃ ត្រូវស្រោចក្នុង១ថ្ងៃ២ដង ត្រូវស្រោចពេលល្ងាច បើស្រោចពេលព្រឹកឬថ្ងៃ បន្ទាប់ពីស្រោចបានរយៈពេល១០នាទី ត្រូវស្រោចទឹកធម្មតាលាងស្លឹកវាវិញ។ ជីប៉ូវនេះវាអាចទាក់ទាញសត្វមានប្រយោជន៍ដូចជាឃ្មុំ ឱម៉ាល់ និងស្រាំងជាដើម។

## ច-ការប្រមូលផល

១) ពេលសាឡាត់មានអាយុបាន៣០-៣៥ថ្ងៃ គេចាប់ផ្តើម ប្រមូលផលបានហើយ (ពីសាបដល់ប្រមូលមាន៣៥ថ្ងៃ)។

២) មុនពេលដកប្រមូលផលត្រូវផ្អាកស្រោចទឹក១ថ្ងៃ

៣) ការដកត្រូវដកពេលព្រឹកឬល្ងាច តែពេលល្ងាចវាប្រសើរជាងពេលព្រឹក។

៤) របៀបប្រមូលត្រូវប្រើកូនចបជីកឬកាំបិតច្រិបចាក់ឫសរួចចាប់ដកវារួចរលាស់ដីផង។

៥) ត្រូវដាក់វាក្នុងម្លប់រួចលាងទឹកគល់វាឲ្យបានស្អាត បន្ទាប់មកដាក់វាទៅក្នុងជាលដោយមានទ្រាប់ស្លឹកចេកដោយទុកចន្លោះឲ្យមានខ្យល់ចេញចូលផង៕

**សូមអរគុណ**

រៀបចំដោយ លោក យុគ សឿង នាយករងរបស់អង្គការស៊ីអារ៍ឌីណាស់ (CRDNASE)
កែសម្រួលអត្ថបទដោយ ស៊ុន សុគន្ធី មន្ត្រីគម្រោងរបស់អង្គការស៊ីអារ៍ឌីណាស់ (CRDNASE)